តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ឮអ្វីខ្លះទាក់ទងនឹងរឿងអស់នេះ?

នៅក្នុងរឿងមុនៗដូចជារឿងរបៀនងងឹត រឿងជួរសម្បុរ រឿងបាតដៃខ្មៅ យើងបានដឹងពីរឿងពិតគួរអោយភ្ញាក់ផ្អើលមួយចំនួន។ ចំណែកពេលនេះ ខ្ញុំមានរឿងពិតមួយថ្មីរបស់គ្រួសារ លោក តន តារា និងភរិយា សារ៉ាយ ស៊ីលាភ មានកូនស្រីម្នាក់ឈ្មោះ តន រមនា បានបាត់ខ្លួនទៅក្នុងឱកាសបោះជំរំមួយ។

-----------

សូរមនុស្សសើច?.....មនុស្សដូចមានច្រើនគ្នា ហើយលាន់មកម្តងឆ្ងាយ ម្តងហាក់នៅជិតត្រចៀកបង្កើយ។ មិនយូរប៉ុន្មាន សំណើចស្រាប់តែលាន់មកហាក់ដូចជានៅក្បែរៗក្រៅបង្អួចនេះឯង?

ម៉ោងប៉ុន្មានហើយ អ្នកណាមកសើចក្បែរនេះធ្វើអី មិនដេកមិនពួនទេ?

ខ្ញុំប្រមូលអារម្មណ៍ត្រឡប់មកវិញយឺតៗ ទាំងមិនចង់ទេ ព្រោះលក់ស្កុងល្អ ប៉ុន្តែស្នូរទាំងអស់នោះពិតជារំខានហួស វាដាស់ខ្ញុំឡើងមកទាល់តែបាន។

អ្វីដែលធ្វើបន្ទាប់ គឺបើកភ្នែកសន្សឹមៗ។ ទីបំផុតខ្ញុំស្គាល់ថា ខ្លួនឯងកំពុងនៅកន្លែងណាហើយ។

ដោយងៀងភ្នែកទៅរក ស៊ីលាភ ខ្ញុំដឹងថាភរិយាខ្ញុំនៅគេងស្កប់ស្កល់នៅឡើយ។

«អាកាសធាតុនៅទីនេះល្អណាស់! តែវាជាតំបន់ភ្នំ? ពីណាគេមកសើចលេងទាំងក្រុមនៀក?»

ម៉ោងប៉ុន្មានហើយ?

ស្ងាត់ច្រៀប មិនឮអីទាំងអស់! យប់ស្ងាត់ណាស់ ស្តាប់ឮតែសូរលាន់ទ្រហឹងនៃបណ្តាក្អាត់សត្វល្អិតល្អោច កណ្តាលរាត្រីកាលនៃវស្សានរដូវ ខ្ញុំចង់បិទភ្នែកទៅវិញ គឺបិទភ្លាម ដៃក៏ទាញភួយដណ្តប់ឱ្យភរិយាផង សាជាថ្មីដែរ។

មួយដង្ហើមនៃការទម្រេត ខ្ញុំចាប់ឮសូរ មនុស្សសើចទាំងហ្វូងទាំងក្រុមសាដើម ហាក់បីដូចជាពួកគេកំពុងធ្វើបុណ្យអីមួយ ម្តងឮជាសំឡេង ម្តងភ្លេង ម្តងឮមនុស្សនិយាយគ្នាចំអន់សើច។ ទោះបីស្តាប់មិនយល់ន័យ ប៉ុន្តែដូចជា សប្បាយក្អាកក្អាយហើយមិនមែនមនុស្សតិចនោះទេ។ ខ្ញុំបើកភ្នែកឡើងវិញខ្វាក។ នៅខាងក្រៅបង្អួចកញ្ចក់ ខ្ញុំដូចជាឃើញមែកឈើបោករញ្ជួយ? ហេតុអីបានជាមែកឈើបោករញ្ជួយចូលគ្នា ប្រហែលនឹងសភាពព្យុះព្យោ?

អ្វីមួយបានធ្វើឱ្យខ្ញុំស្វាងលែងនឹកចង់ងោកងុយបន្ត។

មួយរំពេច សោះខ្ញុំក្រោកដើរមកដល់មាត់បង្អួចបានដូចជប់។

រឿងដែលរឹតតែមិនយល់ គឺ ម៉េចក៏ក្រឡេកមើលទៅខាងក្រៅឃើញច្បាស់ដូចថ្ងៃ? កណ្ដាលយប់យន់ បណ្ដាដើមឫស្សីដែលកាលពីល្ងាចនេះខ្ញុំបានចតផ្ចិតផ្ចង់ ទុកថាជាបរិវេណព្រៃឫស្សីស្រស់ស្អាតបណ្ដាច់ដូចក្នុងរឿងព្រេងចិន ឥឡូវនេះក្លាយទៅជាព្រៃខ្មៅបោករំជួលចុះឡើង?

.....ខ្ញុំយល់សប្ដិទៀតហើយ!

មានអារម្មណ៍ថា អ្វីម្យ៉ាងនៅខាងក្រៅ?

ចម្ងាយប្រមាណជាមិនដល់ដប់ម៉ែត្រពីក្រោយបង្អួចនេះ ខ្ញុំដូចជាឃើញអ្វីម្យ៉ាង? អណ្ដូងមកពីណា? ដូចជាអត់ឃើញអណ្ដូងទេកាលទើបមកដល់ពីថ្ងៃ?

ហេតុអីបានជាពេលនេះធ្លាក់ចូលក្នុងយល់សប្ដិទៀតហើយខ្ញុំ?

វាត្រឹមជាយល់សប្ដិ ពិតណាស់! ខ្ញុំមិនចង់រវល់ទេ!

បណ្ដាដើមឫស្សីក៏ស្រាប់តែ រំពេចនេះញែកផ្លូវចេញជាជួរ ដើម្បីឱ្យខ្ញុំអាចមើលត្រង់ទៅមុខ ឃើញអណ្ដូងមួយនៅក្រោមពន្លឺកាំរស្មីផ្លេកបន្ទោរកណ្ដាលរាត្រី។

អណ្ដូងដ៏ចាស់មួយនៅទីនោះ ដូចជាប្រផ្នូលអ្វីម្យ៉ាងទាញមុខខ្ញុំងាកមកវិញលែងហ៊ានបន្តសម្លឹងវា។

«អណ្ដូងខាងលិច? គេមិនដែលទុកអណ្ដូងទឹកលិចផ្ទះទេ ទម្លាប់នៅស្រុកខ្ញុំ តាំងពីដើមរៀងមក! ពួកយើងតែងតែជឿថា អណ្ដូងនៅខាងលិចផ្ទះគឺជាប្រផ្នូលមិនល្អមួយ! ហេតុអីបានជាឥឡូវ អណ្ដូងដែលយើងមិនបានឃើញពីថ្ងៃសោះ បែរជាមកឃើញនៅក្នុងពេលនេះ?!»

ទោះដឹងថា ខ្ញុំយល់សប្ដិមួយរយភាគរយ ទោះចិត្តមានសំណួរស្មុគស្មាញ តែខ្ញុំមិនចង់រកចម្លើយទេ ខ្ញុំចង់ភ្ញាក់ដឹងខ្លួនឡើងវិញណាស់ អត់ចង់បន្តឡើយ.....

«លោកគ្រូ! លោកគ្រូ! លោកគ្រូតារា! មករាំជាមួយពួកខ្ញុំដែរ? រាំជាមួយពួកខ្ញុំមក!»

គឺជាសំឡេងក្មេងៗដែលស្រែកហៅខ្ញុំពីចម្ងាយ ប្រដាក់គ្នាហៅ។ អូយ! ហៅឈ្មោះទៀត! បេះដូងក្ដុកទៅក្នុងអន្លង់នៃភាពភ័យស្ពឹក។

ក្បាលខ្ញុំធំរីកមាឌឡើងៗ ព្រោះទទួលដឹងអំពីប្រផ្នូលមិនល្អមួយ។ ដៃវារវកបន្ទោងភ្លុក!

អត់នៅទីនេះទេ! វត្ថុស័ក្ដសិទ្ធិរបស់ខ្ញុំ ចាំបានថា បានប្រគល់ទៅឱ្យកូនស្រីខ្ញុំ រមនា ពាក់វាមុនពេលនាងចេញបោះជំរំ។

«លោកគ្រូៗៗៗ មកៗ លោកគ្រូ!»

សំឡេងពួកគេបង្អួសៗ ហើយហៅមិនចេះហត់សោះ។

ខ្ញុំងើបមុខទាំងបែកញើសស្អិត សម្លឹងទៅក្នុងព្រៃឫស្សីដែលជាប្រភពនៃសូរសំឡេង។

ពីនេះទៅក្រៅ ពីរបាំងកញ្ចក់មួយ គឺយើងនៅឆ្ងាយពីគ្នាថែមទៀត សូម្បីតែឫស្សីបោកបក់យ៉ាងនេះខ្ញុំមិនឮសំឡេងទង្គិចនៃពពួកមែកឫស្សីផង ចុះហេតុអីបានជាខ្ញុំឮសំឡេងហៅឈ្មោះ ច្បាស់ៗម្ល៉េះលោកព្រះ?

មិនយូរប៉ុន្មាន នៅនឹងភ្នែកស្រស់ដែលស្រឡាំងកាំង ក្មេងប្រុសតូចល្អិតៗ ពីរជួរបង្ហាញខ្លួនជាមួយក្បាច់រាំខ្មែរបុរាណរំពើតរំពើន។ ជួរទាំងទ្វេមានប្រភពមកពីអណ្ដូងនោះ។ ទោះបីថា ខ្ញុំមើលមិនសូវច្បាស់ដោយសារពឹងតែលើពន្លឺផ្លេកបន្ទោរម្ដងៗ ក៏ភាពម្ដងងងឹតម្ដងភ្លឺនោះនៅតែមានចេតនាឱ្យខ្ញុំផ្ទង់ឃើញពួកគេ។

«ក្មេងៗស្លៀកក្បិនឬក៏អ្វី បានជាខ្ញុំឃើញនៅក្រោមចង្កេះរបស់ពួកគេហាក់ដូចជារីកធំ?»

ក្មេងប្រុសៗនេះ ស្ថិតនៅក្នុងសភាពខ្មៅងងឹតទាំងអស់ តែអារម្មណ៍បានប្រាប់មកថាពួកគេកំពុងរាំនិងបន្ត ហើយស្រែកហៅខ្ញុំនូវពាក្យដដែលៗថា «រាំជាមួយពួកខ្ញុំទេលោកគ្រូ? រាំជាមួយពួកខ្ញុំទេ?»

ខ្ញុំលើកដៃច្បូតមុខទាំងយកសើមជោកដូចស្រោចទឹកដាក់។

ដឹង! នេះគ្រាន់តែជាយល់សប្តិប៉ុណ្ណោះ ប៉ុន្តែចុះយល់សប្តិអីក៏យូរម្ល៉េះ វែងម្ល៉េះ? ខ្ញុំប្រាកដចិត្តណាស់ហើយថា រឿងបែបនេះមិនដែលមាននៅក្នុងជីវិតពិតទេ។ មនុស្សដែលរាំជាជួរហើយបង្ហាញខ្លួននៅកណ្ដាលអាធ្រាត្រ ជាក្មេងប្រុសហើយសំខាន់បំផុត មានប្រភពចេញពីទីអណ្ដូងមួយ ដែលខ្ញុំមិនបានឃើញទៀតកាលពីថ្ងៃ។

ខ្ញុំងាកមករកភរិយា ប៉ុន្តែនៅលើគ្រែលែងឃើញនាងហើយ!

ខ្ញុំមិនឃើញនាងទៀតទេ!

ស៊ីលាភ!

ខ្ញុំហៅនាងដោយភិតភ័យ ប៉ុន្តែហៅមិនចេញសំឡេងសោះ ប្រហែលមកពីខ្ញុំគាំងភ័យ? ក្នុងចិត្តខ្ញុំពិតជា តឹងណែនទ្រូង ខណៈស្នូរគោះទ្វារ ផ្ដើមបង្កើនសេចក្ដីថប់បារម្ភឱ្យខ្ញុំ។

តុៗ.....រន្ថើនឡើងៗ ស្នូរគោះមួយនេះ ដូចមនុស្សកំពុងខឹងសម្បា?

ខ្ញុំដកភ្នែកចោលគ្រែដែលបាត់ស្រមោលភរិយា!

នាងចេញទៅក្រៅពីពេលណា? ម្តេចមិនរវល់នឹងខ្ញុំ មិនឃើញខ្ញុំឈរត្រង់ណេះទេ? ចេញទៅធ្វើអីថ្មើរណេះ? ហើយប្រពន្ធខ្ញុំឯណាមកគោះទ្វាររន្ថើនម្ល៉េះ?

ដោយងាកទៅបែរសម្លឹងចំទ្វារវិញម្តង ខ្ញុំមិនទាន់ឆ្លើយអ្វីទាំងអស់! សួរក៏ខ្ញុំមិនសួរ! សម្តីលោកតាឆ្មុំ ដែលអ្នកផ្ទះខ្ញុំកោតគោរពផ្តាំមកថា «មនុស្សគោះទ្វារយប់ស្ងាត់ រង់ចាំគ្រប់៧ដងសឹមលាន់មាត់រក!» «មនុស្សហៅឈ្មោះយើងកណ្តាលយប់ ទោះស្គាល់មិនស្គាល់ ហាមដាច់ខាតមិនឱ្យឆ្លើយបាទចាស!» ។

ជាមួយពិភាល់សឹងផ្ទុះ ខ្ញុំនៅគាំងសាជាថ្មី ទន្ទឹមនឹងនៅកន្ទុយភ្នែកខ្ញុំដូចជាឃើញ អ្វីម៉្យាងនៅក្រៅបង្អួច។ ខ្ញុំមិនបានគិតទេ ដឹងតែថាខ្លួនឯង ស្រាប់តែសម្លឹងទៅកាន់ទីនោះសាជាថ្មី។

ម្តងនេះ ក្មេងប្រុសទាំងពីរជួរបាត់ស្រមោលបែរជាខ្មោចប្រពន្ធខ្ញុំឈរនៅក្រៅនោះទៅវិញ?

ខ្ញុំចាប់ផ្តើមស្លន់ស្លោ!

អារម្មណ៍ក្នុងពេលនេះ ពិតជាពិបាកពន្យល់ណាស់! ញាណមួយ ខ្ញុំដឹងថានេះមិនមែនជាជីវិតពិត ប៉ុន្តែក៏មិនមែនជារឿងល្អដែរ!

«ស៊ីលាភ» ខ្ញុំខំស្រែកអស់ពីកម្លាំងកាយចិត្ត អស់ពីបេះដូង ព្រោះប្រពន្ធខ្ញុំដើរយឺតៗតម្រង់ទៅរកព្រៃនោះ។

ដៃខ្ញុំតំណាលគ្នាក៏បើកបង្អួចចេញ ដោយសារបង្អួចនេះ ជាប្រភេទកញ្ចក់រុញចំហៀង មិនមានរនាំងបាំងតូចៗល្អិតទេ ខ្ញុំលូកដៃទៅក្រៅព្យាយាមទាញនាងមកវិញ ហើយមាត់បន្តស្រែកហៅខ្លាំងៗផង ប៉ុន្តែប្រពន្ធខ្ញុំនៅតែមិនងាក មិនខ្វល់ ដូចមិនឮ។

សាជាថ្មីខ្ញុំឃើញខ្លួនឯងរត់យ៉ាងលឿន ទៅតាមប្រពន្ធខ្ញុំ មិនដឹងចេញតាមទ្វារឬតាមណាទេ នៅពេលដែលខ្ញុំកាន់តែជិត ប្រពន្ធខ្ញុំកាន់តែរហ័សរហួនហើយអណ្តែតទៅមុខបាត់ តាមលំនាំក្មេងប្រុសទាំងពីរជួរ។

ទីបំផុតនៅសល់តែព្រៃព្រឹក្សាងងឹតស្លុបស្ងាត់ជ្រងំ។

ហេតុអី? មានរឿងអី? ហេតុអីបានជាពួកគេបាត់?

មកដល់មាត់អណ្តូងដោយ មិនដឹងខ្លួន។

ដោយមិនមានចិត្តចង់ឃើញអណ្តូង នោះសូម្បីតែមួយភាគណាទេ ខ្ញុំពិតជាភ័យណាស់ ចង់ត្រជាក់ស្ពឹកអស់ហើយរាងកាយរបស់ខ្ញុំ តែសូរសំឡេងអ្វីម្យ៉ាង ទួញសោកព្រឺព្រួច គួរឱ្យខ្លាចលាន់មកពីខាងក្រោម។

ទីបំផុតខ្ញុំបានធ្វើរឿងដែលខ្ញុំមិនចង់ធ្វើ គឺឱនសម្លឹងក្នុងអណ្តូង ព្រោះខ្ញុំពិតជាឮសូរសំឡេងប្រពន្ធខ្ញុំយំនៅខាងក្រោមនោះ!

ខ្ញុំមិនឃើញអ្វីទាំងអស់! អណ្តូង ឃើញតែភាពខ្មៅស្រអាប់នៅខាងក្រោម ប៉ុន្តែខ្សែសម្រាប់យោងទឹកឡើងមក ចាប់ផ្តើមរំញោចរង្គើ។

ខ្ញុំស្លន់ស្លោ!

«ជួយខ្ញុំផង! ជួយផង!»

ប្រពន្ធខ្ញុំហៅពីក្រោមនោះមក!

បើអ្នកណាម្នាក់ជាខ្ញុំ ច្បាស់ណាស់ក៏នឹងមានប្រតិកម្មដូចគ្នា គឺលូកដៃទទេ ទាញវាឡើងមក ព្រោះគិតថាគឺប្រពន្ធខ្ញុំកំពុងឆ្លេឆ្លាចង់ឡើងមកលើវិញ! ដូច្នេះហើយ ខ្ញុំចាប់ផ្តើមប្រើអស់កម្លាំងកាយកម្លាំងដើម្បីយោងយកនាង។

ធ្ងន់មែន!

ខ្ញុំខំណាស់ពេញមួយទំហឹងកូនប្រុស! ពេលវត្ថុខាងក្រោមនោះឡើងមកដល់កៀកមែនទែនហើយ ទើបខ្ញុំដឹងថា មិនមែនស៊ីលាភទេ ជាក្មេងប្រុសម្នាក់ទៅវិញ! ក្មេងប្រុសម្នាក់កំពុងតែតោងខ្សែនោះឡើងមក ពេលដែលចិត្តខ្ញុំតក់ស្លុត ក៏នៅមិនទាន់ទម្លាក់វាចុះក្រោមវិញនៅឡើយ ទោះគិតថានឹងទម្លាក់ តែមិនទាន់ដាច់ចិត្ត! ក្មេងនោះងើបមុខមកសម្លឹងខ្ញុំឃ្មាំងខ្ញុំភ្ញាក់ព្រើត.....

«អាMan?»

Man គឺជាឈ្មោះនៅផ្ទះរបស់កូនប្រុសស៊ុន មិត្តសម្លាញ់របស់ខ្ញុំ។

ដៃក្មេងប្រុសនោះគ្រាន់តែត្រូវបានខ្ញុំហៅឈ្មោះក៏លែងដៃខ្លួនវា ធ្លាក់ត្មោលទៅក្នុងអណ្តូងវិញយ៉ាងជ្រៅតាមសំឡេងដែលខ្ញុំឮ។

ខ្ញុំគាំងដៃជើង បើកមាត់ស្រែកមួយទំហឹង.....

## វគ្គ សុបិន

បានហើយ! ភ្ញាក់ឡើងវិញរួចហើយ! អស់អីហើយ! តែ.....ម៉ោងជិតបួនភ្លឺ?

នាឡិកាលោតលេខនៅក្បែរដំណេកខ្ញុំ បង្ហាញពេលវេលាធំៗ។ ភ្លឺហើយ! អស់អីហើយ!

ប្រមូលស្មារតីបានមកវិញសន្សឹមៗ ខ្ញុំនឹកឃើញឡើងវិញ។ តាមពិតទៅ ពួកយើងបានមកស្នាក់អាស្រ័យ ទុកថាជាដំណើរកំសាន្តមួយនៅក្នុងព្រៃឫស្សីនេះ ជារីសតដែលប្អូនជីដូនមួយខ្ញុំបានកក់ទុកឱ្យ ពួកយើងពីរគ្រួសារនេះ សម្រេចចិត្តមកកម្សាន្តក្បែរៗ កន្លែងបោះជំរំរបស់កូនៗពួកយើង។

កូនស្រីខ្ញុំ នាងឈ្មោះ រមនា មានអាយុដប់ពីរឆ្នាំ ហើយនិងកូនប្រុសរបស់ស៊ុន មានអាយុដប់ ឆ្នាំឈ្មោះថា Man គឺជាក្មេងដែលខ្ញុំឃើញនៅក្នុងអណ្តូងពេលយល់សប្តិដ៏អាក្រក់អម្បាញ់មិញ។

ពេលនេះម៉ោងជិតបួនភ្លឺហើយ។

ស៊ីលាភកំពុងសម្លឹងមកខ្ញុំដោយបារម្ភ។ ពេលនេះឃើញវត្តមានភរិយាខ្ញុំនៅចំពោះមុខ ខ្ញុំដកដង្ហើមវែងស្រលះខ្លួន ព្រោះបានធូរចិត្តច្រើនណាស់។

ទោះភ្នែកនាងចង់សួរខ្ញុំ តែនាងមិនហាមាត់ទេ! ខ្ញុំថើបគេមួយខ្សឹតដូចរាល់ដង បង្ហាញថា ខ្ញុំនេះមិនអីទាំងអស់។ ខ្ញុំមិនមានបំណងថា នឹងនិយាយចែកចាយពីរឿងយល់សប្តិយល់សូងជាមួយអាលាភស្រាប់ហើយ ព្រោះនាងមិនយកចិត្តទុកដាក់ទេ ខ្ញុំដឹង។

ខ្ញុំចាកចេញពីគ្រែទៅបន្ទប់ទឹក!

«មិញស្រែកឮណាស់!» នាងនិយាយដោយសើចតិចៗ!

«យល់សប្តិអាក្រក់!» ខ្ញុំឆ្លើយតិចៗតបវិញ ដូចស្មាន ស៊ីលាភមិនសួរបន្ថែមទេ។

ខ្ញុំដឹងចិត្តស៊ីលាភ គេជាមនុស្សមិនសូវជឿរឿងទាំងអស់នោះ ប៉ុន្តែគេតែងតែបារម្ភចំពោះខ្ញុំ។ យូរមកហើយខ្ញុំមិនដែលមានសុបិនមិនល្អអ៊ីចឹងទេ ហើយជិតភ្លឺទៀត?

ទឹកលុបមុខបានជួយខ្ញុំឱ្យស្វាងចេញពីសភាពហត់នឿយតាំងពីក្បង់ដំបូងម្ល៉េះ! ទោះបីយ៉ាងណា នៅតែចិត្តមួយបន្តនឹកភ្នកដល់ក្មេងៗ គឺកូនៗពួកយើងដែលទៅបោះជំរំ។

«ឈប់គេងហើយ?!»

ខ្ញុំសួរព្រោះឃើញគេរៀបចំគ្រែ។

«អូនទៅហាត់ប្រាណជាមួយជីណា!»

ជីណាឈ្មោះភរិយារបស់អាស៊ុន និងជាម្ដាយរបស់ក្មួយMan។

តាមប្រលោះស្លាបព្រិលដែលមានបិទផ្ទាំងកញ្ចក់ក្នុងរចនាប័ទ្មយ៉ាងស្អាតនៃបន្ទប់ទឹកនេះ ខ្ញុំមើលឃើញពន្លឺថ្ងៃព្រាងៗលើមេឃ តែនៅមិនទាន់ភ្លឺច្បាស់ល្អបង្ហាញថាព្រឹកព្រហាមថ្មីមកដល់ពេញលេញនៅឡើយ។

«តិចទៀតបងហៅអាស៊ុនទៅក្រវែលមើលជំរំកូនសិន ចាំត្រឡប់វិញបានញ៉ាំអាហារពេលព្រឹក! មិនបាច់ចាំពួកបងទេ!»

ខ្ញុំប្រាប់ប្រពន្ធដែលបែរខ្នងនោះ។

ស៊ីលាភ មិនបានឆ្លើយទេ ប៉ុន្តែយោងទៅតាមខោអាវដែលប្រពន្ធខ្ញុំកំពុងតែស្លៀកពាក់ ខ្ញុំដឹងថាគេបានរៀបចំខ្លួននឹងចេញទៅហាត់យោគៈតាមទម្លាប់របស់គេ។

«បងឯងទៅអង្គុយលេងជាមួយស៊ុនកុំនៅជិតៗគ្នាពេក ស៊ុនជក់បារីណាស់!»

ស៊ុនជាមិត្តសម្លាញ់របស់ខ្ញុំតាំងពីក្មេង។ ស្គាល់គ្នាមិនមែនធម្មតាទេ គឺតាំងពីមិនទាន់ចេះស្លៀកខោ។ ចរិតជក់បារីរបស់យើងទាំងពីរគឺខ្លាំងប្រហែលគ្នា ប៉ុន្តែខ្ញុំផ្ដាច់ជោគជ័យ២ឆ្នាំហើយ។ លើកលែងតែវាអាស៊ុន ដែលកំពុងតែអង្គុយបែរខ្នង នៅឯខ្ទមស្បូវមួយគ្មានជញ្ជាំង ផ្ទុកដោយបណ្ដាកៅអីតុសាឡុងសម្រាប់ភ្ញៀវអង្គុយលេងចោមព័ទ្ធដោយផ្កានិងដើមហូបផ្លែត្រឈៃ។

ចំណែកជីណាប្រពន្ធគេ ក៏ស្លៀកពាក់ខោអាវហាត់ប្រាណរបៀបដូចប្រពន្ធខ្ញុំដែរ។ ស្រីៗទំនងជាមានរឿងច្រើននិយាយគ្នា តាមតែពួកគេទៅ!

«ក្រោកព្រឹកម្ល៉េះអ្ហា!»

ខ្ញុំសួរពីចម្ងាយទៅហើយបិទទ្វារបន្ទប់ ចាក់សោដើរទៅរកវា។ ស៊ុនងាកមករកខ្ញុំទាំងសម្លឹងខ្ញុំពីលើដល់ក្រោមដែរ ព្រោះនៅស្លៀកខោអាវដេកដៃវែងជើងវែង។

«អញយល់សប្ដិមិនល្អ!»

ខ្ញុំនិងអាស៊ុនតាមពិត ការមានសុបិនមិនល្អ តែងតែជាចំណុចខ្សោយនៅក្នុងជីវិតរបស់ពីរនាក់យើង តាំងពីនៅក្មេងៗមក។

ដោយសារប្រវត្តិដើមរបស់ពួកខ្ញុំ មានបង្កប់នូវរឿងរ៉ាវអតីតកាលមួយចំនួនពាក់ព័ន្ធច្រើនជាមួយនឹងអំពើអាបធ្មប់ សុទ្ធតែជារឿងចាស់ៗឧស្សាហ៍នាំយើងនិយាយ តែក្រោយពេលយើងចេះស្រលាញ់ស្រី ហើយមានប្រពន្ធកូន ក៏មិនសូវមានពេលបានជួបជជែកគ្នារឿងអស់នេះទៀតដែរ។

ពេលដើរចូលទៅជិតមែនទែន មិនមែនស៊ុននៅតែម្នាក់ឯងទេ គេកំពុងត្រូវព្រោកប្រាជ្ញជាមួយបុរសចំណាស់ម្នាក់ ខ្ញុំស្គាល់ថា គាត់ជាអ្នកជួយមករឺយែរឡានឱ្យយើងកាលពីពេលមកដល់ល្ងាចមិញ។

បុរសចំណាស់ងាកមកខ្ញុំ ស្របពេលស៊ុនតឿនគាត់៖

«និយាយទៀតពូ!»

ខ្ញុំអង្គុយចុះសន្សឹមៗនៅក្បែរពួកគេ ប៉ុន្តែបុរសចំណាស់ដៀងភ្នែកសម្លឹងមើលខ្ញុំពីលើដល់ក្រោមដូចកាលពីម្សិលមិញដែរ។

«លោកក្មួយស៊ុនក្រោកមកមុនខ្ញុំផង!»

ខ្ញុំញញឹមមិនមាត់។ ស៊ុនហើយរុញកែវកាហ្វេក្ដៅៗហុយទ្រលោមរបស់គេមកឱ្យខ្ញុំ។

«ផឹកមុនទៅ ចាំអញទៅឆុងថ្មីមួយទៀត!»

ខ្ញុំទទួលយកមកភ្លាម ដៃទាំងពីរលើកមកក្រេបក្បឿកៗ។ បុរសចំណាស់សម្លឹងការក្រេបកាហ្វេរបស់យើងដោយស្ងើច គាត់បន្ទរ៖

«អ្នកភ្នំពេញប្រសប់កាហ្វេណាស់ ខ្មៅ ចាស់ ហើយអត់ស្ករទៀត!»

«បាទ!»

ខ្ញុំញញឹមឆ្លើយខ្លី ស្វាគមន៍ការចង់ជជែកលេងរបស់គាត់ ទាំងមិនមានចិត្តថា ចង់និយាយអ្វីច្រើនជាមួយមនុស្សប្លែកមុខទេ។ ចិត្តមួយ ចង់ឱ្យគាត់ចេញសិន នឹងអាលបានជជែកពីយល់សប្តិរបស់វា អាស៊ុន។

ស្រាប់តែពូនោះវាចាមួយៗ៖

«កាលមុនមានពាក្យតំណាលមកថា តែងមានឡានក្រុងមួយមកកាត់តាមណេះ! អ្នកភូមិជុំវិញ ជឿលើពាក្យចចាមអារ៉ាមដែលប្រាប់តៗមកថាឡានទោះ ជាឡានខ្មោច! ជាឡានដែលធ្លាប់គ្រោះថ្នាក់កាលពី

ជាង២០ឆ្នាំមុនពេលដឹកនាំក្រុមល្ខោនបាសាក់មួយក្រុមទៅសម្តែង! គេថារឿងរាល់យប់រនោចខែផល្គុន ឡាននោះបង្ហាញខ្លួនឡើង! ចាស់ៗថា មានមនុស្សឃើញវាកាលណា រឿងអពមង្គលនឹងកើតមានក្នុងភូមិស្រុក!»

«ដែលមានអ្នកឃើញឡានក្រុងនោះទេពូ? ចង់និយាយថា ពេលដែលពួកគាត់ទុក ពាក្យចចាមអារ៉ាមឡានក្រុងនោះមកបានដល់ទៅ២០ឆ្នាំ អាចជាការពិតកម្រិតណា? ទំនងមានអ្នកភូមិធ្លាប់ឃើញក្រោយមក?!» ខ្ញុំសួរគាត់ព្រោះស្លុង ក្បាលកំពុងគិតឃើញបណ្តើរៗឡើង នូវបណ្តារូបភាពអ្នកបាសាក់ពីជំនាន់នោះ។ តាមពិត ខ្ញុំជាមនុស្សពូកែស្រមៃឃើញណាស់ ស្តាប់ភ្លាមក៏ឃើញជាសណ្ឋានជារូបបាន។

ពូសម្រាលសំឡេងនិយាយតបមកវិញ៖

«ធ្លាប់! មានអ្នកល្បាតម្នាក់បានឃើញវា! ជាស្ត្រីផង! ឮថាបានឃើញឡានហ្នឹង! ប៉ុន្តែគាត់មិនបានឡើងជិះទោះបីអ្នកនៅក្នុងនោះ ហៅយ៉ាងណាក៏ដោយ!!»

«ហើយ ចុះបើឡើងជិះទៅយ៉ាងម៉េចពូ?!» អាស៊ុនសួរទាំងកន្ទុយបារីនៅមាត់ឆ្អឹម។

«ឮគេនិយាយថា បើសិនឃានឡើងជិះនឹងបាត់ខ្លួនរហូត! ដូចកាលពីឆ្នាំប៉ែតជាង ធ្លាប់មានអ្នកបាត់ខ្លួនច្រើននាក់ណាស់ក្មួយ ដោយសារតែព្រមឡើងឡាននោះជិះទៅជាមួយគេ!»

«ពូ ជឿដែរអត់?!»

ខ្ញុំសួរបកទាំងខ្លួនឯងនេះ ពាក់កណ្តាលជឿ ពាក់កណ្តាលមិនជឿ គិតថាដូចជាបុរាណពេក គ្រប់យ៉ាងអាចថាបន្លាចតគ្នា? ប៉ុន្តែ...ដំណើរទឹកមុខរបស់គាត់ និងការស្ងៀមស្ងាត់របស់ស៊ុន ដូចជាធ្វើឱ្យខ្ញុំចាប់អារម្មណ៍ថានៅក្នុងចំណោមពួកយើងបីនាក់មានតែខ្ញុំម្នាក់ទេតែពាក់កណ្តាលជឿ។

«អូ! សុំចេញទៅស្រោចស្ពៃសិនក្មួយ!»

«បាទ!»

បុរសចំណាស់ចាកចេញទៅ ចំណែកអាម៉ាកខ្ញុំ បន្តអង្គុយជក់ហុយទ្រលោម។ សម្រាប់អ្នកដទៃមើលមកស៊ុន បើសិនជាគេមិនស្គាល់ គេនឹងគិតថាមិត្តខ្ញុំនេះ ជាកំពូលអ្នកញៀនបារីខ្លាំងមិនខាន។ តែសម្រាប់ខ្ញុំ ឱ្យតែវាជក់ហុយទ្រលោមបែបនេះ ប្រាកដណាស់ ក្នុងចិត្តវាតុកសិក។

«ដូចស្មុគម៉េះអា្ហ?!»

សម្លាញ់ខ្ញុំមិនឆ្លើយ ខ្ញុំសួរទៀត៖

«អ្ហែង ជឿសម្ដីពូមិញ?»

«អញយល់សប្តិមិនល្អសោះ អាវ៉ា!»

ស៊ុនឆ្លើយខ្លីៗសំឡេងមិនស្រណុកចិត្តទេ។ ខ្ញុំក៏នៅស្ងៀមលែងនិយាយស្ដី ពីព្រោះតាមពិតទៅអ្នកដែលយល់សប្តិមិនល្អពិតប្រាកដគឺខ្ញុំ ហើយពាក់ព័ន្ធជាមួយរឿងស្ដែងៗឃើញមុខកូនប្រុសតែមួយគត់របស់មិត្តខ្ញុំទៀត។

មិនទាន់អីផង ឪពុកនៅឯណោះស្រាប់តែបង្ហាញនូវអាការៈ មិនសប្បាយចិត្តទាំងសកម្មភាពជក់បារីនិងទឹកមុខស្លេកស្លាំង។

ខ្ញុំបោះបង់គំនិតដែលថា ចង់និយាយរឿងអណ្ដូងខាងលិចជាមួយអាស៊ុនចោល ហើយលើកកាហ្វេមកក្រេបទៀតបន្លប់ទឹកមុខខ្លួនឯង។

ស៊ុនងាកចុះងាកឡើង ឈប់ជក់បារីទៀតដោយបោះកន្ទុយដែលនៅសល់ពាក់កណ្ដាលនោះចោល។

«យល់សប្តិឃើញអីខ្លះអ្ហា?»

ខ្ញុំសួរ តែសម្លាញ់ខ្ញុំហាក់នៅទីទើរមិនចង់និយាយ។ បានបន្តិចខ្ញុំក៏គោះស្មាវា ដោយដូរមកលួងលោមវិញ៖

«កុំជឿសម្ដីពូហ្នឹងពេក! អាចថា គាត់និយាយពិតចុះ ប៉ុន្តែរឿងអបិយជំនឿអស់ហ្នឹង ធម្មតាពាក់ព័ន្ធខ្លាំងតែជាមួយអ្នកជឿស៊ុបទេវ៉ី! អ្នកមិនជឿ មិនដែលឃើញស្អីទាំងអស់! ឡានក្រុងស្អីឯង? សម័យអ៊ីនធឺណេតទៅហើយ!»

ទោះប្រហើរលេងសម្រាលវាហើយក៏ចិត្តនៅតែលួចគិត។ បើសិនជាខ្ញុំនិយាយអំពីរឿងអណ្ដូងខាងលិចទៀត មិនដឹងជាក្នុងចិត្តវាទៅជាយ៉ាងម៉េចទៀតទេ ពីព្រោះនៅក្នុងចំណោមអ្នកស្រុកយើងតំណមអំពិលនៅត្បូងអណ្ដូងនៅលិចគឺជាតំណមធំមួយ។

ជាក់ស្ដែង មានការចងចាំខ្លាំង តាមរយៈហេតុការណ៍ជាច្រើនដែលពីរនាក់ខ្ញុំធ្លាប់ជួបផ្ទាល់កាលពីនៅក្មេងៗ។

«សម្ដីពូចាមនិយាយមិញនេះ មិនមែនជារឿងលេងសើចទេអាវ៉ា!»

ស៊ុននិយាយមកតិចៗតវ៉ា។ ចំណែកខ្ញុំ ទើបនឹងចាប់អារម្មណ៍ថា ពូអម្បាញ់មិញនេះ តាមពិតឈ្មោះថា ពូចាម។

«ហើយមិនទាន់អីផង ស្គាល់ឈ្មោះគាត់ច្បាស់ណាស់អ្ហ៎! និយាយគ្នាអត់ដេកពួនដឹង?!»

ខ្ញុំសួរវាទាំងតាមមើលដំណើរពូចាម កំពុងឃ្នូរធុងទឹកស្រោចដំណាំ២ ដើរកាត់មុខយើងតម្រង់ចម្ការនៅទិសខាងត្បូង។

ស៊ុនឆ្លើយតបមកខ្ញុំវិញ៖

«ពុកម៉ែប្រដៅថា ទៅណាមកណាគួរទម្លាប់និយាយលេងជាមួយអ្នកស្រុក មានទំនាក់ទំនងល្អ មានការអីគេនឹងជួយយើង!»

«និយាយឡើងធ្វើមើលតែត្រៀមនឹងមានរឿងអ៊ីចឹងអ្ហ៎!!»

«អញយល់សប្តិឃើញក្មេងៗមានរឿង!»

ស៊ុនតបមកភ្លាមដោយខ្សឹបៗ។

ពេលឃើញថា ខ្ញុំនេះយកចិត្តទុកដាក់ផ្ទៀងស្តាប់ក្រឡង់ៗ សម្លាញ់អាប់ម្នាក់នេះ ចាប់និយាយបន្តជាប់មាត់រដឹកប្រាប់មកខ្ញុំខ្សឹបខ្សៀវល្មមតែឮបានពីរនាក់៖

«អញឃើញខ្លួនអញកំពុងធាក់កង់សំដៅទៅរកកន្លែងក្មេងៗបោះតង់ តែទៅដល់ គ្មានឃើញមនុស្សមួយទេ!»

មុខខ្ញុំស្មើ ដូចកំពុងផ្ចង់ស្តាប់វា ឯចិត្តវិញវិលខ្វាល់បាចសាច។ តាមថា នេះជាដំណើរបោះជំរំលើកទីបីហើយសម្រាប់សាលារៀនរបស់កូនៗយើង ប៉ុន្តែខ្ញុំនិងអាស៊ុន មិនដែលអនុញ្ញាតកូនទៅនឹងគេទេ។

រហូតដល់លើកនេះខ្ញុំសម្រេចចិត្តឱ្យមក មកដោយសារតែការទទូចអង្វររបស់រមនា ហើយនិងការយល់ព្រមរបស់ស្រីលាភ ប្រពន្ធដ៏មានគំនិតទាន់សម័យរបស់ខ្ញុំ។

គេនេះគឺជាមនុស្សស្រីដែលមិនជឿលើអាគមអូមអាម ព្រោះគេមិនដែលជួប ចំណែករមនាគឺមិនចេះខ្លាចអ្វីៗទាំងអស់។

ភរិយាខ្ញុំនាង ចង់លើកទឹកចិត្តឱ្យកូនស្រីបានដើរហើរ បានស្គាល់នូវដំណើរឆ្ងាយពីផ្ទះ មានបទពិសោធន៍រឹងមាំ ហើយលើកនេះ មិនមែនខ្ញុំមិនទុកចិត្តអំពីប្រព័ន្ធការពារដែលខាងសាលាហៅគេធានារ៉ាប់រងនោះទេ ប៉ុន្តែបានប្អូនប្រុសជីដូនមួយខ្ញុំឈ្មោះឫទ្ធី ដែលគេស្គាល់តំបន់នេះច្បាស់ គេថានៅក្នុងវាលឫស្សីនេះ មានរីសតថ្មីមួយ អាចជាបទពិសោធនៃការស្នាក់នៅដ៏ត្រជាក់ សុខដុមរមនា បរិយាកាសប្លែកពោរពេញទៅដោយធម្មជាតិ ក៏នៅក្បែរៗជំរំកូនដែរបានជាយើងព្រមព្រៀងគ្នាមក។

ទីនេះខុសពីតំបន់ភ្នំនានា ជំរំរបស់ក្មេង បោះនៅប្រមាណជាជាង៥០០ម៉ែត្រពីកន្លែងស្នាក់របស់ពួកខ្ញុំ ដោយឆ្លងកាត់ វាលស្មៅតូចមួយ និងផ្ទះអ្នកស្រុកមួយចំនួន។ ដោយសារតំបន់នេះ ប្អូនប្រុសខ្ញុំប្រាប់ថា មានសុវត្ថិភាពព្រោះភូមិសាស្ត្រមានច្រកចេញចូលតែមួយ គ្មានទីណាផ្សេងឡើងមកបានម៉្លោះហើយ មនុស្សអាក្រក់មិនអាច គេចខ្លួនងាយស្រួលនោះឡើយ។

ពួកគេមិនដែលមានករណីព្រហ្មទណ្ឌ កើតមានឡើងនៅក្នុងតំបន់នេះទេរយៈពេលដប់ម្ភៃឆ្នាំចុងក្រោយនេះ ពោលគឺចាប់តាំងពីចេញពីសង្គ្រាមមក។

ខ្ញុំទើបតែដឹងថា ទីនេះគឺ ភូមិឫស្សីស្វាយ។ ទោះជា ដើមឫស្សីទាំងអស់ ហាក់មិនមានពណ៌ស្វាយដូចគេល្បីមែន តែរាល់ពេលចាំងនឹងពន្លឺថ្ងៃអាទិត្យអស្តង្គត ព្រៃឫស្សីពិតជារំលេចចេញនូវទិដ្ឋភាពយ៉ាងប្រណីតកម្រនឹងបានឃើញ។

រឿងអណ្តូងមួយនោះ បានផុសសាជាថ្មីក្នុងគំនិតនិងភាពស្ងៀមស្ងាត់របស់ខ្ញុំ។

«អញឃើញខ្លួនឯងទៅដល់ជំរំមួយស្ងាត់សូន្យ! ពេលដាក់កង់ទុក អញដើរមើលតាមតង់ ទទេស្អាតគ្មានមនុស្សទាំងអស់!»

សម្តីវាធ្វើឱ្យខ្ញុំនឹកឃើញឡើងវិញនូវសកម្មភាពដដែលនេះកាលពីល្ងាច ពេលដែលយើងទើបបានមកដល់ ខ្ញុំនិងស៊ុនបានធាក់កង់ ទៅមើលទីនោះមែន។

ការរៀបរាប់របស់ស៊ុនបញ្ជាំងឡើងវិញក្នុងអារម្មណ៍ខ្ញុំនូវជំរំមួយ មានតង់ប្រមាណជា៣០ទៅ៤០តែគ្មាននរណានៅ?

ស៊ុនរៀបរាប់បន្តៈ

«អ៊ីចឹងអញភ័យស្លឹតស្លក់ ស្រែកហៅរកអាManនិងគ្រូភាព! បន្ទាប់មកឃើញខ្លួនឯងរត់ វង្វេងវង្វាន់គ្មានដឹងកន្លែងណាជាកន្លែងណាព្រោះក្នុងតង់ទទេទាំងអស់! នៅតង់ចុងក្រោយអញចាប់ផ្តើមឮសំឡេងត្រដរខ្យល់! ពេលអញទៅដល់ ហើយបើកវាមើល ទៅជាឃើញមនុស្សព្រៃម្នាក់ ឱបកូនឈ្លូសមួយត្រដរខ្យល់នៅក្នុងដៃ! អញស្រែកដូចឆ្កួតវង្វេងដល់ដឹងខ្លួនឡើង! អ្ហែងកាត់សប្តិអញម៉េចដែរអ្ហ៎ាអាវ៉ា?!»

ខ្ញុំចាប់ផ្តើមដកដង្ហើមវែងៗ រភ្នែកសម្លឹងជុំវិញនេះមិនមាត់អ្វីទាំងអស់។

អាស៊ុនម្នាក់នេះ ធ្លាប់ត្រូវខ្មោចចូលកាច់ដៃកាច់ជើងជាច្រើនដងតាំងពីនៅក្មេងៗ រហូតដល់បានអាយុជិតដប់ឆ្នាំទើបអាចរកគ្រូមកមើលត្រូវ។

ពីដំបូងៗពួកម៉ាកកម្សត់របស់ខ្ញុំម្នាក់នេះត្រូវគេល្បីពេញភូមិនោះថា កើតរោគឆ្កួតជ្រូកឬគ្រាសកន្លង។ ពុកអាស៊ុនគាត់យកកូនទៅពេទ្យខាងសរសៃប្រសាទរាប់ដងភ្លេច ពេលខ្លះត្រូវវាគេចង ពេលខ្លះត្រូវគេ បំពាក់នូវឧបករណ៍ ដើម្បីស្ទង់កម្រិតនៃការគិត និងបញ្ហាខួរក្បាល។

ម្តងៗវាធ្វើទុក្ខ ខ្ញុំជាអ្នកឃើញផ្ទាល់ភ្នែកហើយមានអារម្មណ៍វេទនាជំនួស អាណិតវាណាស់។ មិននឹកស្មានថាក្រោយមក អ្នកស្រុកក៏ជួយរកឃើញពីរឿងអំពើដែលម្តាយចុងឃោរឃៅរបស់វា ដាក់អំពើមន្តអាគមទៅលើខ្លួនវា ប្រាថ្នាយកទ្រព្យសម្បត្តិដីចម្ការរបស់ពុកវា។

ដោយសារតែរឹងទទឹងមិនព្រមទទួលស្គាល់កំហុស ព្រមទាំងមិនព្រមដោះអំពើនោះចេញឱ្យកូនដើមវិញ មីងនោះក្រោយមកត្រូវគេនិយាយថា ឈឺស្លាប់ខ្លួនឯងដោយសារ «អំពើបកមករកម្ចាស់ដើម»។

រឿងនេះ អ្នកភូមិរបស់យើងជឿខ្លាំងណាស់ ទាក់ទងជាមួយនិងមន្តអាគមអំពើងងឹត គេនិយាយគ្នាមិនស្ងាត់ទេ។

ក្រោយមកម្តាយខ្ញុំ បានរាប់អានលោកតាម្នាក់ឈ្មោះធុំ។ គាត់ជាអ្នកចេះរបៀនតមកពីជីដូនជីតាគាត់ច្រើនជំនាន់មកហើយ។ ដោយសារការស្រលាញ់រាប់អានគាត់បានឱ្យភ្លុកមួយមកខ្ញុំពាក់ក ហើយគាត់ថានេះជាមន្តស័ក្តិសិទ្ធិអាចថែរក្សាខ្ញុំបាន។

ខ្ញុំងើបមើល ទៅខ្សែករបស់អាស៊ុន នៅលើកកវា។

ពីនៅក្មេងយើងពាក់ជាខ្សែអំបោះតែពេលធំឡើងមានប្រពន្ធរៀងខ្លួន ពួកយើងប្រើបន្តោងភ្លុកនេះជាមួយនឹងខ្សែកមាស តែម្តង។

ដោយសារតែលោកតាធុំលែងនៅ គាត់បានទៅកាន់ឋានសួគ៌បាត់ ខ្ញុំធ្លាប់អុជធូបបន់ស្រន់បួងសួងស្បថស្បែថា ខ្ញុំដឹងអាស៊ុនសំគមកម្សត់នេះ ជាមិត្តភក្តិស្លាប់រស់ និងបានសុំគាត់យកភ្លុកនេះមកឆ្លាក់ជាពីរចំណែក គឺជាបន្ទះម្ខាងសម្រាប់វា ម្ខាងសម្រាប់ខ្ញុំពាក់ការពារខ្លួន។

«ចុម! ហើយពួកបងឯងបានកាហ្វេខ្មៅឈ្ងុយពេញព្រៃភ្នំទាំងព្រឹកទៀត?!»

សំឡេងមកដល់របស់ឫទ្ធីប្អូនជីដូនមួយខ្ញុំ។ វាពត់ដៃ ពត់ខ្លួនប្រាណនិយាយបន្តពីក្រោយខ្នងស៊ុន៖

«អាកាសធាតុល្អដល់ហើយ! ខ្ញុំស្រលាញ់តំបន់អ៊ីចឹងណាស់!»

តាមថាឫទ្ធីត្រូវមកដល់តាំងពីយប់មិញប៉ុន្តែមិនដឹងថាដោយសារហេតុអីបានជាព្រលឹមស្រាងៗទៅហើយទើបឃើញមុខ?

«យប់មិញអាល័យធ្វើអី? ពួកអញ ចាំដល់យប់ជ្រៅ!»

ឫទ្ធីធ្វើមុខស្រងូតឆ្លើយ៖

«អាពីនឈឺ! ខ្ញុំនាំទៅព្យួរសេរ៉ូម! ឥឡូវនេះបានគ្រាន់បើ គេមិនចង់មក គេទៅគេងផ្ទះម៉ែគេហើយ!»

អាពីននេះគឺជាសង្សាររបស់ឫទ្ធី។ ទោះបីថាប្អូនប្រុសជីដូនមួយខ្ញុំជាមនុស្សខិលខូច មានសង្សារច្រើន ឧស្សាហ៍ដោះដូរដៃគូចុះឡើង ប៉ុន្តែពីនគឺជាមនុស្សស្រីដែលគ្រប់គ្នាស្គាល់ហើយឃើញថា នៅជាមួយគេបានយូរជាងអ្នកមុនៗ។

ប្រហែលជាដោយសារនាងឈឺហើយបានជា មិនឃើញឫទ្ធីមកដល់វីសតនេះកាលពីយប់មិញ។

«ឯងទៅមើលគេទៅ? មកធ្វើអី?!»

«មានអី! ខ្ញុំមកជួយកំដរពួកបងឯង!»

ខ្ញុំដឹងថា ឫទ្ធីកន្លងមកស្រលាញ់ក្មួយខ្លាំងណាស់ គឺក្មួយស្រីរមនារបស់គេ ជាកូនស្រីខ្ញុំ។ គេទៅណាមិនដែលចោលទេរមនា។

ខ្ញុំនឹកឃើញដល់ត្រង់នេះ ក៏ភ្នកគិតដល់កូនស្រីដែលមានលក្ខណៈសម្បត្តិប្លែកខុសពីក្មេងនានា។ បានអាយុប្រាំពីរឆ្នាំ កូនខ្ញុំចាប់ផ្ដើមមានសកម្មភាពចម្លែកៗ ដែលពីដំបូងខ្ញុំមានអារម្មណ៍ភ័យខ្លាច ចេះតែគិតវែងឆ្ងាយ ក្រែងលោកូនជួបរឿងស្មុគស្មាញដូចកាលអាស៊ុននៅក្មេង ប៉ុន្តែរឿងដែលខ្ញុំនឹងធូរចិត្តគឺខ្ញុំនេះមិនដែលមានប្រពន្ធចុង ឬក៏ស្រីស្នេហ៍លួចលាក់អ្វីទេ។

ស៊ីលាភនិងខ្ញុំគឺជាគូស្នេហ៍ស្មោះស្ម័គ្រ ស្រលាញ់ចិត្តនិងចិត្តរហូតបានជួបគ្នា គឺតស៊ូសម្បើមណាស់ពីព្រោះឪពុកម្ដាយរបស់ស្រីលាភគឺជាអ្នកទាន់សម័យ ហើយចំណែកគ្រួសារខ្ញុំគឺជាអ្នកស្រែចម្ការ។

និយាយពីកូនស្រីរបស់ខ្ញុំ ចាប់ពីបានអាយុប្រាំពីរឆ្នាំ គេចូលចិត្តនៅស្ងៀមស្ងាត់ ម្ដងម្កាលដូចជាចេះស្មឹងស្មាធិ៍ម្នាក់ឯងផងក៏ថាបាន។

ភរិយារបស់ខ្ញុំវិញ គឺជាអ្នកជំនាញផ្នែកគណនី ធ្វើការនៅធនាគារធំមួយ នាងមិនសូវមានពេលទំនេរច្រើន ថែមទាំងមិនមានជំនឿលើផ្នត់គំនិតបុរាណនានាទេព្រោះមិនធ្លាប់ជួប។ ណាមួយនាងជា

កូនអ្នកទីក្រុង រាល់ពេលដែលខ្ញុំតំណាលពីរឿងអាស៊ុនកាលពីនៅក្មេង ស៊ីលាភនៅស្ដាប់ ប៉ុន្តែខ្ញុំមិនដែលដឹងថា នាងជឿដែរឬអត់ទេ។

ដោយសារបែបនេះ ករណីកូន គឺនៅឆ្ងាយពីចំណាប់អារម្មណ៍របស់ស៊ីលាភ។

ខ្ញុំបានសាកល្បងរកវិធីសាស្ត្រនិយាយជាមួយកូនស្រីខ្ញុំដោយខ្លួនឯងបាន និងស្ងាត់ៗ។ ទីបំផុតខ្ញុំបានដឹងតាមរយៈកូនស្រីខ្ញុំដែលបានសារភាពប្រាប់ខ្ញុំត្រង់ៗថា គេគឺជាមនុស្សដែលដឹងរឿងអ្វីៗជាមុន។ គេមានសមត្ថភាពពិសេស គឺអាចមើលដឹងអនាគតណាដែលពាក់ព័ន្ធនឹងរឿងអកុសល នៃគ្រួសារខ្លួន មនុស្សជិតដិត ប្រសិននាងចង់ដឹង មិនតែប៉ុណ្ណោះ រមនាថែមទាំងអាចធ្វើសមាធិហើយឆ្លើយឆ្លងជាមួយមនុស្សនៅឆ្ងាយពីគ្នាបានទៀត។

សម្រាប់ខ្ញុំ កុំថាឡើយដល់អ្នកដទៃណាដែលពិបាកពិភាក្សារឿងនេះជាមួយ សូម្បីតែប្រពន្ធរបស់ខ្ញុំ បើឱ្យនាងដឹង ច្បាស់ជាភ័យឡូឡាពេញផ្ទះទាមទារយកកូនទៅឱ្យពេទ្យចិត្តសាស្ត្រមើលមិនខាន។

ជាឪពុកម្នាក់ ខ្ញុំពិចារណាអ្វីៗដែលកើតឡើងលើកូនស្រីខ្ញុំ ដោយប្រយត្ន័ប្រយែង។ មិនត្រឹមជួបពិភាក្សាជាសម្ងាត់ជាមួយពេទ្យចិត្តសាស្ត្រ សូម្បីតែគិតរឿងដូចដែលអ្នកភូមិរបស់ខ្ញុំធ្លាប់ជឿ គឺ«ការចូលរូប» «ស្នងរូប» «ទាយាទផ្លូវងងឹត» អីទាំងអស់នេះ រឹតតែរំខានអារម្មណ៍ខ្ញុំរហូតមក។

ខ្ញុំបាននិយាយជាមួយនាង ដូចជាមិត្តម្នាក់ គឺខ្ញុំបានអត់ធន់សព្វបែបយ៉ាងជាមួយ អ្វីៗប្លែកៗ ដែលនាងប្រាប់មកខ្ញុំ។ ខ្ញុំចង់ឱ្យរមនាចែករំលែករឿងទាំងនោះដោយស្មោះត្រង់ជាមួយខ្ញុំ ម្ល៉ោះហើយខ្ញុំរើសយកការអង្កេតពិនិត្យសន្សឹមៗមកធ្វើជាដំណោះស្រាយជាក់ស្ដែង គឺដោះម្ដងមួយដំណាក់ៗ។

ពាក្យចុងក្រោយដែលយើងបាននិយាយគ្នាល្ងាចម្សិលមិញ គឺថា នេះជាដំណើរឆ្ងាយពីប៉ា លើកដំបូងក្នុងជីវិតនាង ទោះណាជាមានរឿងអីកើតឡើង កូនមិនភ័យទាំងអស់ព្រោះប៉ានៅស្នាក់ក្បែរៗ។

ស្រាប់តែនាងខ្សឹបប្រាប់ខ្ញុំថា បើមានអ្វីកើតឡើង «កូននឹងស្មិងស្មាធិ៍ហើយមកនិយាយបញ្ជាប្រាប់ប៉ាជាមុន!»

ខ្ញុំត្រូវភាំង ព្រោះកើតភ័យទាំងគ្មានមូលហេតុចំៗទេ តែព្រោះឮពាក្យឆ្លើយអស់ទាំងនេះ។

ផ្អាកខ្ញុំចេញពីការគិតទៅដល់រមនា ស៊ុនឱនមកនិយាយជាមួយខ្ញុំតិចៗ៖

«អ្អែងចង់ទៅមើលជំរំជាមួយអញដែរ?!»

ភ្នែកខ្ញុំក្រឡេកឃើញឫទ្ធីកំពុងតែ ដើរក្រពាត់ក្រឡឹងមើលតង់មួយ ពូម្នាក់ឈ្មោះ«ចាម» បានរៀបចំនៅក្បែរបន្ទប់ពួកយើងសម្រាប់ឱ្យគេ។

ឬទ្ធីទំនងជា គិតថាមិនចង់ចំណាយច្រើនបានជាយប់មិញសម្រេចចិត្តគេងតង់ក្បែរមុខបន្ទប់ខ្ញុំ តែយប់មិញមិនបានមកទុកតង់ចោល។

«គោះ!! តែអញដូរខោសិន»

ខ្ញុំឆ្លើយខ្លីជាមួយស៊ុនហើយក្រោកតម្រង់ទៅបន្ទប់។ ក្នុងនោះខ្ញុំក្រេបទឹកមួយក្បៀក ហើយឆ្លៀតលបមើលទៅព្រៃឬស្សីខាងក្រោយ។ គ្មានអណ្ដូងគ្មានអីទេ។ ធូរចិត្តវិញហើយ ព្រោះយល់សប្ដិវាគ្រាន់តែជាយល់សប្តិ មិនយកជាការបានទេ។

ចេញមកវិញ ខ្ញុំដើរបកទៅរកកង់ពីរបីដែលគេទុកស្រេចសម្រាប់ភ្ញៀវជិះហ្វ្រី។

ស៊ុនបានរង់ចាំខ្ញុំស្រេចនៅលើផ្លូវ។ មើលពីនេះទៅ ពួកម៉ាកខ្ញុំនេះបានថែមអាវរងាក្រៅមួយជាន់ទៀត ដែលអាវនោះមានជាប់ជាមួយមួកគ្របក្បាលជិតផង។

នៅក្រោមភាពព្រិលស្រអាប់នៃចំហាយសន្សើមត្រជាក់ពេលព្រហាម គ្មានពន្លឺថ្ងៃ មិនដល់មួយបទចម្រៀងចប់ស្រួលបួល យើងទាំងពីរធាក់កង់មកដល់តំបន់ដែលមានជួរពន្លឺអំពូលសូឡានៅជះស្រទន់ខ្លះ ច្បាស់ខ្លះ គម្លាតពីគ្នាប្រមាណជាប្រាំម៉ែត្រមួយ។

ទីនេះបានប្រាប់ខ្ញុំនូវអារម្មណ៍អ្វីមួយប្លែកថា គ្រប់យ៉ាងមិនដូចការរំពឹងរបស់ខ្ញុំពេលដែលជិះមកនោះទេ។ ដៃខ្ញុំចាប់ផ្ដើមបានរោយស្ពឹកលើដៃកង់។ ម្ដងៗកំភួនដៃខ្ញុំព្រឺសម្បុរ។ អារម្មណ៍ថាគ្រប់យ៉ាងមិនប្រក្រតីនៅក្នុងជំរំនេះ កើតច្បាស់ឡើងៗនៅពេលអាស៊ុនងាកមកសួរខ្ញុំខ្សឹបៗសឹងចេញចំហាយត្រជាក់តាមដង្ហើម៖

«ចុម ស្ងាត់ម៉េះអ្ហា ថ្មើរណេះហើយ?!»

ហេតុអ្វីមើលទៅគ្មានវត្តមានមនុស្សមានជីវិតសូម្បីតែម្នាក់?

ខ្ញុំមិនមាត់មិនឆ្លើយតែចាប់ផ្ដើមចុះពីលើកង់ថ្នមៗពីព្រោះថា ជារឿងមិនល្អមួយផ្នែកសីលធម៌ប្រសិនបើក្មេងៗចេញមក ឃើញពីរនាក់យើងជិះកង់កាត់ជម្រកស្នាក់នៅរបស់ពួកគេ។

ដើរបណ្ដើរកង់ផង ខ្ញុំព្យាយាមធ្វើឱ្យមានសូរច្រវាក់ខ្លាំងៗ ឱ្យមានសំឡេង ឯពួកម៉ាកខ្ញុំក៏ហួចឡើងសង្ឃឹមក្រែងមានអ្នកណាម្នាក់បានឮ នឹងចេញមកសួរនាំពួកយើង ខ្ញុំក៏នឹងមានឱកាសក្នុងការដឹងអំពីពួកក្មេងៗដែលកំពុងដេក។

«អត់ស្រួលទេ អារ៉ា!»

ស៊ុនខ្សឹបទៀត។

ពួកយើងអូសកង់អោយលាន់ច្រវាក់ផង ហួសរកផងនៅតែគ្មាននរណាម្នាក់លេចមុខចេញសោះ។

«គ្រូភាពគួរតែក្រោកហើយអ្នាថ្មើរណេះ!»

ខ្ញុំតបទៅស៊ុនដោយដើរឆ្លងពីមុខតង់ដំបូងមួយ។ ដ្បិតតែវាបិទ ប៉ុន្តែខ្យល់មួយរឹប បានបង្ហើបចំណុចគែមខាងស្តាំ ធ្វើឱ្យខ្ញុំមើលទៅឃើញខាងក្នុង ស្រពេចស្រពិលដោយសារពន្លឺសូទ្បា។

«ខាងក្នុងដូចជាគ្មានមនុស្សទេ?»

ខ្ញុំគិតហើយឈប់ជើងខាងមុខមុខតែម្តង។ ដោយចាប់ផ្តើមបុកពោះខ្ញុំវាយជន្ទល់កង់ដើរទៅមើលឱ្យជាក់សឹមញាក់ចិញ្ចើម។

កាលពីវ័យជំទង់ ពួកយើងធ្លាប់មើលកុនច្រើនរឿងណាស់ទាក់ទងនឹងមនុស្សព្រៃ ឬអំពើវាយប្រហារគ្រោះថ្នាក់នានាលើអ្នកបោះតង់ ពេលនេះគ្រប់យ៉ាងលាន់មកបន្លាចក្នុងការចងចាំដែលខ្ញុំកំពុងបញ្ចាំងសាដើមឡើងមកដោយបង្ខំក្នុងគំនិតខ្លួនឯង។

«អឺ បង?!»

ខ្ញុំហៅតិចៗ។ ដ្បិតតែគ្មានឈ្មោះ តែខ្ញុំសំដៅហៅគ្រូៗដែលដឹកនាំការបោះជំរំនេះ រួមមានគ្រូសុភាព គ្រូម៉ាឌុន និងអ្នកគ្រូនីកា។

«គ្មានមនុស្សម្នាក់!»

ស៊ុនបន្ទោសទាំងមួហ្មងធ្វើឱ្យខ្ញុំងាកក្រោយសម្លឹងវា។ ពួកម៉ាកខ្ញុំអន្ទះសាណាស់ វាដើរវៃកតង់មើលស្តែងៗតែម្តង។ ដឹងថាស៊ុនស្លន់ស្លោដែរ តែហួសពេលឃាត់វាហើយ។ ក្មេងៗទៅណាអស់មេឃមិនទាន់ភ្លឺផង?

ខ្ញុំរវេ្ទកសម្លឹងជុំវិញខ្លួន ម្តងហើយម្តងទៀត មួយជុំហើយមួយជុំទៀត។ អ្នកដែលខ្ញុំស្គាល់ច្បាស់ជាងគេនៅក្នុងបេសកកម្មបោះជំរំមួយនេះ ហើយដែលយើងទើបតែបាននិយាយគ្នាលេងកាលពីល្ងាចម្សិលមិញអំពី កម្មវិធីម៉ោងពេលនៃការបោះជំរំនេះ គឺលោកគ្រូឈ្មោះ សុភាព។

គាត់គឺជាគ្រូនាំមុខដំណើរការបោះជំរំលើកនេះ ក៏ជាអ្នកដែលផ្តល់មកឱ្យខ្ញុំនូវព័ត៌មានកម្មវិធីនានាទាក់ទងថ្ងៃនេះ។

ខ្ញុំចាប់ផ្តើមស្រែករកគាត់៖

«បងសុភាព?!»

គ្មានអ្នកណាឆ្លើយ។ គ្មានសូម្បីសូរដង្ហើមមនុស្សម្នាក់ក្រៅពីយើងទាំងពីរ និងគ្មានសូម្បីតែសំឡេងកម្រើក ឬក៏សំឡេងស្រមុករបស់អ្នកណាម្នាក់សោះ។

ខ្ញុំចុចទូរសព្ទមើលម៉ោង។ ម៉ោងជិតប្រាំហើយ ជិតភ្លឺហើយ ខ្ញុំក៏មិនសូវភ័យ ប៉ុន្តែហេតុអ្វីទីនេះស្ងាត់ឈឹង។

ខ្ញុំចាប់ផ្តើមបែរសំដៅទៅតង់មួយរាងធំទ្រើសជាងគេ នៅចំកណ្តាលជំរំទំនងគ្រូៗទុកអីវ៉ាន់ និំចំណី?

«មានមនុស្ស?»

ខ្ញុំសួរគួរសមមុនពេលអើតទៅមើល។

តង់ទទេ សល់តែសម្រាមខ្លះៗដូចជាកេសទឹកនិងសម្បកមីឆុង។

ថ្មើណេះនេះវាឆាប់ពេកហើយសម្រាប់ការនាំក្មេងៗទៅហាត់ប្រាណ ឬក៏ដើរព្រៃ?

«អ្ហែងមើលណេះ ម៉េចបានបានជានៅក្នុងតង់អត់មានសល់សូម្បីតែសាក់កាដូ ដបទឹក ភួយ ខ្នើយ?»

ស៊ុនហៅខ្ញុំចោលរឹងទៅពិនិត្យតង់ផ្សេងៗជុំវិញនោះ។ ចិត្តខ្ញុំចាប់ផ្តើមឆ្ងេឆ្ងា ស្លន់ស្លោឱនសម្លឹង ខណៈអាស៊ុនលៃងខ្វល់ខ្វាចចិត្តអ្នកណា វាស្រែកឮៗ៖

«អាMAN អីអាMANកូន?!»

ខ្ញុំចុចទូរសព្ទ ប៉ុន្តែគ្មានសេវាទេ។

«អញយល់សប្តិមិនសូវខុសទេ!»

ស៊ុនខ្សឹបពេលវាដើរកាត់ខ្ញុំ។

ខ្ញុំមិនមាត់ ព្រោះចាប់ផ្តើមឮសម្រិបអ្វី ពីឆ្ងាយមកគួរឱ្យចិត្តកើតសង្ស័យ។ ពេលខ្ញុំរវៃភ្នែកទៅរកប្រភពដែលជាកូនតង់ពក្លក់មួយក្រោយគេ គឺនៅចុងផ្លូវបញ្ចប់ អាស៊ុនដើរមកក្បែរ វាចាប់ផ្តើមនៅគាំងផ្ទឹង។

ដូចមនុស្សត្រូវតក់ស្លុតនឹងអ្វីមួយខ្លាំងហួស។

តង់មួយនេះនៅផ្លូវចុង ខាងជើងគេបង្អស់ ដែលពីលើនោះគ្របដណ្តប់ទៅដោយដើមឈើ ត្រសុំធំវិសាល។

«តង់ហ្នឹងហើយអញយល់សប្តិជិតភ្លឺ ឃើញមានមនុស្សអង្គុយបែរខ្នងវា សក់ក្បាលកន្ទ្រើងខ្លួនវាប្រលាក់ឈាម វាសម្លាប់ឈ្លូស!»

ដៃអាស៊ុនញ័រខ្លាំងណាស់នៅក្បែរៗខ្ញុំ ពេលនិយាយរឿងនេះចប់។ ហេតុអីរឿងរ៉ាវទៅជាអ៊ីចឹង? ខ្ញុំស្ទុះលែងអត់ធ្មត់ ឈានសំដៅតង់ដូចជា ខ្លួនឯងនេះដឹងថា អ្វីមួយមិនល្អកំពុងរង់ចាំ យើងតែខ្ញុំនៅតែឈានទៅញាប់ឡើងៗឱ្យដល់ក្បែរទីតាំងនោះ។

ពេលខ្ញុំលើកដៃបើកវាមើល អាស៊ុននៅទ្រឹងពីចម្ងាយដដែល។

គ្មានមនុស្ស គ្មានក្រុមមនុស្សព្រៃដូចនៅក្នុងរឿងកុន ថែមទាំងគ្មានក្លិន គ្មានស្នាមអ្វីគួរឱ្យសង្ស័យទាំងអស់ វាគ្រាន់តែជាសត្វសុនកមួយ។

«ឆ្កែរបស់អ្នកគ្រូនីកា ល្ងាចមិញអញឃើញរត់តាមគាត់!»

ខ្ញុំនិយាយប្រាប់ស៊ុន។

គ្មានការឆ្លើយតបទេ ខ្ញុំក៏ងាកមកអង្អែលក្បាលសត្វហើយជួយវាឱ្យចេញមកក្រៅវិញបាន។ ក្រឡេកមកវិញលើកនេះ ខ្ញុំឃើញក្នុងតង់មានអក្សរបិទមួយផ្ទាំងថា «ក្រុមយើងទៅល្អាងថ្មមាស» ល្ងាចបានមកជំរំវិញ។

ធូរចិត្តខ្សាក.....តែមិនមែន១០០ភាគរយទេ.....

«អ្អែងមើលណែក...»

ស៊ុនហៅខ្ញុំ។

មិត្តខ្ញុំរកឃើញកូនឡានដែករបស់អា Man ដែលកាលពីរនាក់ខ្ញុំទៅប្រជុំនៅស្រុកថៃជាមួយគ្នា ស៊ុនបានស្វែងរកទិញបានមកឱ្យកូនប្រុសគេ ខ្ញុំចំណាំឡាននេះបាន។

មិនសមណាថា ពួកក្មេងៗទៅល្អាងអីទាំងព្រលឹមអុររកតែថ្ងៃរះឡើងក៏មិនទាន់ ហើយមកធ្លាក់ចោលកូនឡានសំណព្វចិត្តនៅឯណេះទៀត?

«ទៅរីសតវិញសិនចាំគិត!»

ខ្ញុំនិយាយទៅកាន់ស៊ុន ព្រោះថាមានតែបកទៅកន្លែងគេងវិញសិន នឹងអាលបានទៅរកសាកសួរអ្នកស្រុកមុនពេលនាំគ្នាចេញទៅរកក្មេងៗដល់នៅល្អាងថ្មមាសនោះ។